**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

លេខ ១៩០ ស.ជ.ណ

ថ្ងៃព្រហ.១៥កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមីនា ឆ្នាំ ២០១៩

# សេចក្តីជូនដំណឹងលើកទី២

## ស្តីពី

## ការអញ្ជើញចូលរួមពិគ្រោះថ្លៃ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញនឹងដាក់ឲ្យពិគ្រោះថ្លៃជាសាធារណៈ ដូចខាងក្រោម៖

- ១-កញ្ចប់"ក"៖ ការផ្គត់ផ្គង់បន្ទះដែកបុកទប់ដី បន្ទះដែកទប់ដី និងក្បាលបុកបេតុង
- ២-កញ្ចប់"ខ"៖ ការផ្គត់ផ្គង់ទឹកអាស៊ីតលាង Cell
- ៣-កញ្ចប់"គ"៖ ការស្តារកក់ជុំវិញស្ថានីយបូមទឹកល្អក់ភូមិព្រែក ផ្នែកខាងត្បូង ខាងជើង និងតាមបណ្តោយមាត់ច្រាំងទន្លេខាងលិចអណ្តូងស្ថានីយបូម

ឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមពិគ្រោះថ្លៃ (រួមទាំងសេចក្តីណែនាំ) មានដាក់លក់នៅអង្គភាពលទ្ធកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលមានអាសយដ្ឋានលេខ៤៥ ផ្លូវលេខ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ចាប់ពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩ តទៅ រៀងរាល់ម៉ោងធ្វើការ (៨ព្រឹកដល់១៦:៣០រសៀល) ដល់ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ ត្រឹមវេលាម៉ោង ១៦:០០រសៀល ក្នុងមួយច្បាប់តម្លៃ ១៦០,០០០រៀល។

កាលបរិច្ឆេទឈប់ទទួល និងបើកសំណើពិគ្រោះថ្លៃគឺ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩ កញ្ចប់"ក"វេលាម៉ោង១៤:៣០នាទី, កញ្ចប់"ខ"វេលាម៉ោង១៤:៥០នាទី និងកញ្ចប់"គ"វេលាម៉ោង១៥:១០នាទី នៅអង្គភាពលទ្ធកម្មនៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ជាន់ទី១) តាមអាសយដ្ឋានខាងលើ។

គ្រប់ពាក្យពិគ្រោះថ្លៃទាំងអស់ ត្រូវភ្ជាប់មកជាមួយនូវប្រាក់កក់ធានាការពិគ្រោះថ្លៃដែលមានចំនួនដូចបានកំណត់ក្នុងឯកសារពិគ្រោះថ្លៃ។

អ្នកពិគ្រោះថ្លៃមានសិទ្ធិជ្រើសរើសកញ្ចប់មួយ ឬទាំងអស់។ ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់សំណើពិគ្រោះថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមពិគ្រោះថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មដើម្បីទិញឯកសារពិគ្រោះថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការពិគ្រោះថ្លៃនេះ (ទូរស័ព្ទទាក់ទងលេខ ០១៧ ៨១១ ៩១១)។

**ជ. គណៈកម្មាធិការលទ្ធកម្ម**
**អនុប្រធានទី១**

បណ្ឌិត.**ជា វិសុទ្ធ**

<u>ចម្លងជូន៖</u>
- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ
  "ដើម្បីជ្រាបជាព័ត៌មាន"
- ឯកសារ-កាលប្បវត្តិ